ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

# ចំណាប់អារម្មណ៍នៃ
# ឯកឧត្តម ម៉ៀ សំអឿន អនុប្រធានទី១ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
# ក្នុងវេទិកាសំរាប់កិច្ចសហប្រតិបត្តិការ អភិវឌ្ឍន៍កម្ពុជា
# ថ្ងៃទី ១៩-២០ ខែ មិថុនា ឆ្នាំ ២០០៧

- សូមគោរព **ឯកឧត្តម គាត ឈន់** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធានទី ១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងជាប្រធានគណៈកម្មាធិការសំរបសំរួល រវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍
- ឯកឧត្តម លោកជំទាវ សមាជិកសមាជិការនៃរាជរដ្ឋាភិបាលកម្ពុជា
- ឯកឧត្តម លោកជំទាវ សហប្រធានក្រុមការងារចំរុះបច្ចេកទេស
- ឯកឧត្តម លោកជំទាវ ឯកអគ្គរដ្ឋទូត ឯកអគ្គរាជទូត តំណាងប្រទេសផ្តល់ជំនួយ
- ឯកឧត្តម លោកជំទាវ លោក លោកស្រី និងតំណាងអង្គការជាតិ អន្តរជាតិក្នុងអង្គពិធី ជាទីគោរព

ថ្ងៃនេះក្នុងនាមថ្នាក់ដឹកនាំនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និង សហប្រធានក្រុមការងារចំរុះបច្ចេកទេសលើវិស័យអេដស៍ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គវេទិកា ដែលបានអនុញ្ញាតខ្ញុំបាទ ធ្វើរបាយការណ៍ពីស្ថានភាពទូទៅនៃជំងឺអេដស៍នៅកម្ពុជាក្នុងអង្គវេទិកានេះ ។

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ជាស្ថាប័នជាតិមានលក្ខណៈជាពហុវិស័យដែលមានបេសកកម្មដឹកនាំ និងអនុវត្តការងារបង្ការ និងទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍នៅកម្ពុជា ។

ស្ថាប័ននេះត្រូវបានបង្កើតឡើង យោងតាមព្រះរាជក្រម លេខ នស /រកម/០៧០២ /០១៥ ចុះថ្ងៃ ទី២៩ ខែកក្កដា ឆ្នាំ២០០២ ដែលបានប្រកាសឱ្យប្រើច្បាប់នេះស្តីពីការបង្ការ និងទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ជំងឺអេដស៍ ។

ដើម្បីបន្តនិរន្តរភាព ក្នុងការអនុវត្តច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍នៅកម្ពុជាឱ្យមានប្រសិទ្ធភាព រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ និងឈ្លាសវៃនៃ **សម្តេច ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី បានសំរេចឱ្យប្រើប្រាស់អនុក្រិតថ្មីលេខ១០៩ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៦ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ហើយដែលអនុក្រិត្យនេះបានផ្តល់វិភាគទានយ៉ាងខ្លាំងក្លាចំពោះការអនុវត្តឱ្យសំរេចបាន និងលើកកំពស់នូវលទ្ធភាពដែលទទួលបានសេវាអេដស៍ជាសកល និងព្រមទាំងអនុវត្តតាមគោលនយោបាយចតុកោណរបស់រាជរដ្ឋាភិបាល និងស្របតាមគោលការណ៍បីចំណុចរបស់អង្គការសហប្រជាជាតិស្តីពីជំងឺអេដស៍ :

- ជាស្ថាប័នគ្រប់គ្រងនិងសំរបសំរួលជាពហុវិស័យតែមួយគត់ក្នុងការប្រយុទ្ធនឹងជំងឺអេដស៍
- ជាស្ថាប័នរៀបចំគោលនយោបាយផែនការយុទ្ធសាស្ត្ររួមមួយសំរាប់ជាមូលដ្ឋានចង្អុលទិសក្នុងការឆ្លើយតបទៅនឹងការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍នៅទូទាំងប្រទេស
- ជាស្ថាប័នតាមដានប្រព័ន្ធព័តិមាននិងត្រួតពិនិត្យតែមួយគត់សំរាប់វាយតំលៃ សកម្មភាព

ខ្ញុំសូមជំរាបថា ប្រទេសកម្ពុជាបច្ចុប្បន្ននេះ បានរួចផុតពីការរាតត្បាតជំងឺអេដស៍ជាទូទៅ ហើយកំពុងស្ថិតនៅក្នុងដំណាក់កាលការរាតត្បាតប្រមូលផ្តុំ។ អត្រាប្រេវ៉ាឡង់បានថយចុះមកនៅ **០.៦ %** ក្នុងឆ្នាំ ២០០៥ ដូចដែលការធ្វើអង្កេតប្រជាសាស្ត្រ និងសុខភាពបានលើកឡើង បើប្រៀបធៀបទៅនឹង **១.៩** % នៅឆ្នាំ ២០០៣ ហើយនិង **៣.៣%** នៅឆ្នាំ ១៩៩៧។

ការដែលរាជរដ្ឋាភិបាលយើងសំរេចអោយមានការបង្កើតក្រុមការងារបច្ចេកទេសចំរុះលើវិស័យអេដស៍ដោយឡែកនេះ គឺជាសក្ខីភាពនៃការយកចិត្តទុកដាក់ ការប្តេជ្ញាចិត្ត និងសុឆន្ទៈនយោបាយនៃរាជរដ្ឋាភិបាលយើងលើវិស័យអេដស៍។

ឯកឧត្តមអតីតអគ្គលេខាធិការអង្គការសហប្រជាជាតិ **កូហ្វី អាណាន់** បានបញ្ជាក់ក្នុងកិច្ចប្រជុំវិសាមញ្ញរបស់អង្គការសហប្រជាជាតិ កាលពីខែមិថុនា ឆ្នាំ ២០០៥ ថា សកលលោកទាំងមូលបានសង្កេតឃើញមានកម្មវិធីបង្ការ និងទប់ស្កាត់ដែលនាំមកនូវជោគជ័យ ដូចជានៅប្រទេស **ប្រេស៊ីល កម្ពុជា** និង **ថៃឡង់** នេះជាជោគជ័យមួយទៀតនៃរាជរដ្ឋាភិបាលកម្ពុជានៅលើឆាកអន្តរជាតិ ហើយក៏

មានប្រទេសមួយចំនួនបានមកធ្វើការសិក្សា និងដកស្រង់បទពិសោធន៍ពីប្រទេសកម្ពុជាយើងផងដែរ ។

ថ្វីបើថវិកាជាតិនៅមានកំរិតក៏ដោយ ជារៀងរាល់ឆ្នាំរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ក្នុងការបង្កើនថវិកាជាតិសំរាប់សកម្មភាពនៃការទប់ស្កាត់ការរីករាលដាលនៃជំងឺអេដស៍ ។ ឧទាហរណ៍រាជរដ្ឋាភិបាលបានសំរេចបង្កើនថវិកាជាតិពីឆ្នាំ ២០០៦ ជា២ដងមកឆ្នាំ ២០០៧ សំរាប់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ហើយដែលអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍គួបផ្សំនឹងថវិកាជំនួយ យើងបានចំណាយលើការប្រយុទ្ធប្រឆាំងនឹងជំងឺកាចសាហាវនេះ ។

នៅថ្ងៃទី២២ ខែកុម្ភះ ឆ្នាំ២០០៦ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានរៀបចំពិធីប្រកាសឱ្យប្រើជាផ្លូវការនូវផែនការយុទ្ធសាស្ត្រជាតិលើកទី២ ឆ្នាំ២០០៦-២០១០ ដែលជាយុទ្ធសាស្ត្រមានលក្ខណៈទូលំទូលាយ និងពហុវិស័យឆ្លើយតបទៅនឹងការរីករាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍ ។

តាមផែនការ យើងបានគ្រោងទុកនៅឆ្នាំ ២០១០នេះដែរ ទាក់ទងនឹងការបង្ការ យើងព្យាយាមធានាថាប្រជាជនគ្រប់ស្រទាប់ជាន់ថ្នាក់ និងគ្រប់ទីកន្លែងបានទទួលចំណេះដឹងពីជំងឺអេដស៍ ពីច្បាប់អេដស៍និងមានលទ្ធភាពគ្រប់គ្រាន់ក្នុងការមកទទួលមធ្យោបាយបង្ការ ដូចជាស្រោមអនាម័យ និងសេវាធ្វើតេស្តឈាម ។ល ។

ថ្មីៗនេះកម្ពុជាបានចូលរួមនៅកិច្ចប្រជុំមហាសន្និបាតវិសាមញ្ញរបស់អង្គការសហប្រជាជាតិ ដែលអង្គប្រជុំក៏បានបញ្ជាក់ថាៈការប្ដេជ្ញាចិត្តរបស់បណ្ដាប្រទេសដែលជាសមាជិករបស់អង្គការសហប្រជាជាតិគឺចាត់ទុកបញ្ហាអេដស៍គឺជាគ្រោះមហន្តរាយពិភពលោកដែលទាមទារនូវអាទិភាពខ្ពស់ក្នុងការបរិច្ចាកថវិកាសំរាប់សកម្មភាពទប់ស្កាត់ការរាលដាលក្នុងទ្រង់ទ្រាយសកលលោកដោយឈរលើគោលការណ៍គោរពសិទ្ធិមនុស្សជាមូលដ្ឋាន ។

សន្និសិទ្ធអន្តរជាតិស្ដីពីជំងឺអេដស៍នៅទីក្រុងតូរ៉ុងតូ ប្រទេសកាណាដាដែលបានបញ្ចប់នាខែសីហាកន្លងទៅថ្មីៗនេះបានកំណត់ទិសដៅថាៈ ចាប់ពីឥឡូវនេះរហូតដល់ ឆ្នាំ ២០១០ គឺត្រូវតែធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋទាំងអស់បានទទួលនូវវិធានការបង្ការការចំលងមេរោគអេដស៍ សេវាថែទាំ និងព្យាបាលជំងឺអេដស៍ ។

កម្ពុជាយើងដែលសំរេចជោគជ័យទទួលបានលើការទប់ស្កាត់ ការរីករាលដាលនៃជំងឺអេដស៍គឺដោយមានការខិតខំប្រឹងប្រែងរួមគ្នាទាំងស្ថាប័ននិតិបញ្ញត្តិ រាជរដ្ឋាភិបាល ព្រះសង្ឃ អាជ្ញាធរដែនដី អ្នកផ្ទុកមេរោគអេដស៍ និងប្រជាជនទូទាំងប្រទេសដោយមានកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរ ជាមួយស្ថាប័នពាក់ព័ន្ធ ប្រទេសផ្ដល់ជំនួយ អង្គការជាតិ អង្គការអន្តរជាតិ ផ្នែកឯកជន និងសង្គមស៊ីវិល ។

ថ្វីត្បិតកម្ពុជាយើងបានទទួលជោគជ័យជាទីមោទនៈក៏ពិតមែននោះ មិនមែនមានន័យថា កម្ពុជាយើងបានទប់ស្កាត់ និងការពារបានទាំងស្រុងនោះទេ ហើយបច្ចុប្បន្ននេះជំងឺអេដស៍ក៏បាន និង កំពុងរីករាលដាល និង សាយភាយពីទីប្រជុំជនរហូតដល់ជនបទទូទាំងកម្ពុជាយើងផងដែរ ។

ដូច្នេះដើម្បីអនុវត្តតាមគោលនយោបាយដែលរាជរដ្ឋាភិបាលប្រគល់ជូនឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ថែមទៀត និងស្របតាមគោលការណ៍ ៣ ចំណុចរបស់អង្គការសហប្រជាជាតិ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នឹងត្រូវខិតខំគៀងគរជំនួយ និងសូមអំពាវនាវចំពោះសហគមន៍អន្តរជាតិ ប្រទេសអ្នកផ្តល់ជំនួយអោយបន្តជំនួយបន្ថែមទៀត ក្នុងកិច្ចសហប្រតិបត្តិការជាមួយកម្ពុជា ដើម្បីបន្តនូវនិរន្តរភាពក្នុងការឆ្លើយតបទៅនឹងការរីករាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍ប្រកបដោយប្រសិទ្ធិភាព ។

យើងសូមឆ្លៀតឱកាសនេះដែរ សូមអរគុណដល់ប្រទេសផ្តល់ជំនួយ និងដៃគូអភិវឌ្ឍន៍នានា ដែលបានផ្តល់ការគាំទ្រចំពោះការឆ្លើយតបទៅនឹងការរីករាលនៃមេរោគអេដស៍/ជំងឺអេដស៍នៅប្រទេសកម្ពុជា រហូតទទួលបានជោគជ័យជាទីមោទនៈសំរាប់ប្រជាជនកម្ពុជា ។

ខ្ញុំបាទសូមអរគុណដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី នៃអង្គវេទិកាទាំងមូលដែលបានស្តាប់របាយការណ៍របស់ខ្ញុំ និងសូមជូនពរឱ្យបានសំរេចជោគជ័យគ្រប់ភារកិច្ច ។

**សូមអរគុណ**